ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ.៥២៥.....សហវ.ប្រក

## ប្រកាសអន្តរក្រសួង
## ស្តីពី
## គោលរបបនិងនីតិវិធីចំណាយថវិកា
## សម្រាប់កម្មវិធីបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**
**រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខនស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី ១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញព្រះរាជក្រមលេខនស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាស ឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៨១ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតការត្រួតពិនិត្យហិរញ្ញវត្ថុលើការចំណាយថវិការដ្ឋនៅតាមក្រសួង ខេត្ត ក្រុង ក្រុងស្វ័យត រាជធានីភ្នំពេញ និងអង្គការសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St. 92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CABOMDIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone: 855-23-724 664 Fax: 855-23-427 798

- បានឃើញអនុក្រឹត្យលេខ ២៨៣ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យលេខ ១០៥ អនក្រ.បក ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០០៦ ស្តីពីលទ្ធកម្មសាធារណៈ
- បានឃើញអនុក្រឹត្យលេខ៤២៦ អនក្រ.បក ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១៣ របស់រាជរដ្ឋាភិបាលកម្ពុជា ស្តីពីការរៀបចំ និងដាក់ឱ្យអនុវត្តអង្គភាពថវិកា
- បានឃើញប្រកាសលេខ២៣៧ សហវ.ប្រក ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០០៦ ស្តីពីការដាក់ឱ្យប្រើប្រាស់គោលការណ៍ណែនាំស្តីពីការរៀបចំថវិកាកម្មវិធី
- បានឃើញប្រកាសលេខ ១៩១១ សហវ. ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីការដាក់ឱ្យអនុវត្តគោលការណ៍ណែនាំស្តីពីនីតិវិធីអនុវត្តថវិកាកម្មវិធី
- បានឃើញប្រកាសអន្តរក្រសួងលេខ២៩៣កបប្រ ចុះថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០១៤ ស្តីពីការដាក់ឱ្យអនុវត្តអង្គភាពថវិកា រវាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងការងារនិងបណ្តុះ បណ្តាលវិជ្ជាជីវៈ

**សម្រេច**

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**ប្រការ១.~**

ប្រកាសអន្តរក្រសួងនេះ មានគោលដៅកំណត់គោលរបបនិងនីតិវិធីអនុវត្តចំណាយថវិកាសម្រាប់កម្មវិធីអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈនៃក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ។

**ប្រការ២.~**

ប្រកាសអន្តរក្រសួងនេះ មានគោលបំណងសម្រួលនីតិវិធីនៃការអនុវត្តចំណាយថវិកា សម្រាប់កម្មវិធីអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ដើម្បីធានាឱ្យការចំណាយមានតម្លាភាព គណនេយ្យភាព និងប្រសិទ្ធភាពខ្ពស់ សំដៅលើកកម្ពស់គុណភាពអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈនៅកម្ពុជា។

**ប្រការ៣.~**

ប្រកាសអន្តរក្រសួងនេះមានវិសាលភាព គ្របដណ្តប់អនុវត្តចំពោះគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ដែលស្ថិតក្នុងក្របខ័ណ្ឌសមត្ថកិច្ចនៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។

## ជំពូកទី ២

## គោលរបបចំណាយថវិកានិងការផ្តល់អាហារូបករណ៍

**ប្រការ៤.~**

មុខសញ្ញាចំណាយសម្រាប់កម្មវិធីអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ រួមមានជាអាទិ៍ សម្ភារបរិក្ខារតូចតាច ឯកសារបង្រៀន សៀវភៅមើល ការផ្សព្វផ្សាយព័ត៌មានអំពីវគ្គបណ្តុះបណ្តាល ឧបត្ថម្ភគ្រូបច្ចេកទេស អ្នកសម្របសម្រួលវគ្គ ប្រជុំ និងពិធីបើក បិទវគ្គបណ្តុះបណ្តាល ។

**ប្រការ៥.~**

មុខសញ្ញាចំណាយ សម្រាប់កម្មវិធីអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ត្រូវកំណត់ផ្តល់ជាកញ្ចប់គោលរបបដោយគិតជាឯកតាសម្រាប់សិស្ស និងនិស្សិតម្នាក់ៗដូចខាងក្រោម÷

- ចំណាយសម្រាប់បណ្តុះបណ្តាលរយៈពេល១សប្តាហ៍ ផ្តល់គោលរបប ចំនួន ១១៣ ០០០ រៀល/សិស្សម្នាក់
- ចំណាយសម្រាប់បណ្តុះបណ្តាលរយៈពេល០៤ខែ ផ្តល់គោលរបប ចំនួន ៤០០ ០០០រៀល/សិស្សម្នាក់
- ចំណាយសម្រាប់បណ្តុះបណ្តាលរយៈពេល០៧ខែ ផ្តល់គោលរបបចំនួន៨០០ ០០០រៀល/សិស្សម្នាក់
- ចំណាយបណ្តុះបណ្តាលសញ្ញាបត្របច្ចេកទេស និងវិជ្ជាជីវៈ១ ២ ៣ រយៈពេល១០ខែ ផ្តល់គោលរបបចំនួន ១ ០០០ ០០០រៀល/សិស្សម្នាក់
- ចំណាយបណ្តុះបណ្តាលសញ្ញាបត្រជាន់ខ្ពស់/បរិញ្ញាបត្ររងបច្ចេកទេស/ឯកទេស រយៈពេល ០២ឆ្នាំ ផ្តល់គោលរបបចំនួន ៦០០ ០០០រៀល/និស្សិតម្នាក់/មួយឆ្នាំ
- ចំណាយបណ្តុះបណ្តាល បរិញ្ញាបត្របច្ចេកវិទ្យា/ឯកទេសសញ្ញាបត្រវិស្វកររយៈពេល(០៤ឆ្នាំ) និងគរុកោសល្យ (០១ឆ្នាំ) ផ្តល់គោលរបប ចំនួន ៧០០ ០០០រៀល/និស្សិតម្នាក់/មួយឆ្នាំ។

**ប្រការ៦.~**

ផ្តល់ប្រាក់អាហារូបករណ៍ពិសេស ដល់សិស្សសិក្សាសញ្ញាបត្របច្ចេកទេស និងវិជ្ជាជីវៈ (កម្រិត ១ កម្រិត២ និងកម្រិត៣ )លើមុខជំនាញអាទិភាពដែលជាតម្រូវការទីផ្សារការងារ។ ការកំណត់មុខជំនាញ និងចំនួនអាហារូបករណ៍ត្រូវជាកម្មវត្ថុនៃការពិភាក្សាគ្នាពេលចរចាថវិកាប្រចាំឆ្នាំនីមួយៗ។

ប្រាក់អាហារូបករណ៍ពិសេសត្រូវកំណត់ផ្តល់គោលរបបចំនួន ១៦០ ០០០រៀល/សិស្សម្នាក់/មួយខែ។

## ជំពូកទី៣

## ការគ្រោងឥណទានថវិកា និងនីតិវិធីនៃការអនុវត្តថវិកា

### ផ្នែកទី១

### ការគ្រោងឥណទានថវិកា

**ប្រការ៧.~**

ឥណទានថវិកាសម្រាប់បណ្តុះបណ្តាលត្រូវគ្រោងក្នុងជំពូក ៦២ គណនី ៦២០៣ អនុគណនី ៦២០៣៦ (ចំណាយសម្រាប់ឧបត្ថម្ភមណ្ឌលស្តារលទ្ធភាពពលកម្ម នីតិសម្បទា និងបណ្តុះបណ្តាលអភិវឌ្ឍន៍)។

## ផ្នែកទី២
## ការបើកផ្តល់សាច់ប្រាក់

**ប្រការ៨.-**

អាណាប័កត្រូវស្នើសុំធានាចំណាយជាកញ្ចប់ប្រចាំឆមាស សម្រាប់ចំណាយកម្មវិធីបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ។ ការបើកផ្តល់សាច់ប្រាក់ត្រូវអនុវត្តតាមនីតិវិធីបុរេប្រទានមួយត្រីមាសម្តង។

**ប្រការ៩.-**

អគ្គនាយកដ្ឋានរតនាគារជាតិ ត្រូវបង្វេរសាច់ប្រាក់ចូលគណនីរបស់អគ្គនាយកដ្ឋានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ឬគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ នៅរៀងរាល់ដើមត្រីមាសនីមួយៗ ទៅតាមកម្មវិធីចំណាយសាច់ប្រាក់ ដោយប្រើប្រាស់ប្រព័ន្ធធនាគារ។

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ត្រូវជ្រើសរើសធនាគារដៃគូណាមួយដោយមានការឯកភាពពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីឱ្យគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ បើកគណនីសម្រាប់កិច្ចប្រតិបត្តិការសាច់ប្រាក់របស់ខ្លួន។

បន្ទាប់ពីទទួលបានការឯកភាពលើការជ្រើសរើសធនាគារ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ត្រូវណែនាំដល់គ្រប់គ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ក្រោមឱវាទ ដើម្បីដំណើរការបើកគណនីរៀងៗខ្លួន និងប្រមូលឯកសារពាក់ព័ន្ធនឹងការបើកគណនីនេះ ដើម្បីបូកសរុបនិងរាយការណ៍ជូនអគ្គនាយកដ្ឋានរតនាគារជាតិ។

## ផ្នែកទី៣
## ការគ្រប់គ្រងថវិកា

**ប្រការ ១០.-**

ប្រធានគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ត្រូវចាត់តាំងមន្ត្រីគ្រប់គ្រងហិរញ្ញវត្ថុ ដើម្បីធ្វើជាសេនាធិការគ្រប់គ្រង និងទទួលខុសត្រូវលើរាល់ការចំណាយថវិការបស់អង្គភាពខ្លួនឱ្យទទួលបាននូវប្រសិទ្ធភាព ស័ក្តិសិទ្ធិភាព តម្លាភាព និងគណនេយ្យភាព។

**ប្រការ ១១.-**

មន្ត្រីគ្រប់គ្រងហិរញ្ញវត្ថុគឺជាមន្ត្រីនៃគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ដែលត្រូវឆ្លងកាត់ការបណ្តុះបណ្តាល អំពីមូលដ្ឋាននៃការអនុវត្តថវិកា និងការកាន់បញ្ជិកាគណនេយ្យ ដើម្បីមានសមត្ថភាពក្នុងការអនុវត្តកិច្ចប្រតិបត្តិការហិរញ្ញវត្ថុស្របតាមវិធាន និងបទប្បញ្ញត្តិហិរញ្ញវត្ថុជាធរមាន។

## ផ្នែកទី ៤
## ការអនុវត្តចំណាយ និង កិច្ចបញ្ជិកាគណនេយ្យ

**ប្រការ ១២.~**

ការអនុវត្តចំណាយសម្រាប់កម្មវិធីអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ត្រូវអនុវត្តតាមវិធាននិងនីតិវិធីហិរញ្ញវត្ថុជាធរមាន ។

**ប្រការ ១៣.~**

គ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ត្រូវរៀបចំរបាយការណ៍ហិរញ្ញវត្ថុដើម្បីស្នើសុំទូទាត់ចំណាយថវិកាបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ ប្រចាំត្រីមាសនៅរៀងរាល់ដើមខែនៃត្រីមាស បន្ទាប់ទៅក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ លើកលែងត្រីមាសទី៤ ដែលត្រូវបញ្ជូនឱ្យបានមុនថ្ងៃទី៣១ ខែធ្នូ នៃឆ្នាំនីមួយៗ ដោយត្រូវភ្ជាប់ឯកសារ លិខិតយុត្តិការ សក្ខីបត្រចំណាយ និងប័ណ្ណចំណាយច្បាប់ដើមត្រឹមត្រូវ និងគ្រប់គ្រាន់។

ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ត្រូវរៀបចំបោះអាណត្តិនិយ័តកម្ម រួចបញ្ជូនទៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីពិនិត្យនិងផ្តល់ទិដ្ឋាការចំណាយតាមនិតិវិធីហិរញ្ញវត្ថុ និងបញ្ជូនទៅអគ្គនាយកដ្ឋានរតនាគារជាតិដើម្បីទូទាត់ជម្រះបញ្ជី។

**ប្រការ ១៤.~**

មន្ត្រីគ្រប់គ្រងហិរញ្ញវត្ថុនៃគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ត្រូវរៀបចំបង់សាច់ប្រាក់ដែលនៅសល់ចូលគណនីទោលរបស់រតនាគារឱ្យបានមុនថ្ងៃទី២៥ខែធ្នូជារៀងរាល់ឆ្នាំ។

**ប្រការ ១៥.~**

មន្ត្រីគ្រប់គ្រងហិរញ្ញវត្ថុរបស់គ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ពុំតម្រូវឱ្យមានកិច្ចបញ្ជិកាទ្វេភាគទេ ប៉ុន្តែត្រូវកាន់បញ្ជីតាមដាន ដូចខាងក្រោម ÷

- បញ្ជីបេឡា (ត្រូវរៀបចំប័ណ្ណចំណូល ប័ណ្ណចំណាយ រាល់ពេលមានប្រតិបត្តិការសាច់ប្រាក់កើតឡើង)។
- បញ្ជីតាមដានសម្ភារ (ត្រូវរៀបចំប័ណ្ណបញ្ចូលសម្ភារទំនិញ ប័ណ្ណបញ្ចេញសម្ភារទំនិញ រាល់ពេលមានសម្ភារទំនិញចេញចូល)។

## ជំពូកទី៤

## អន្តរប្បញ្ញត្តិ

**ប្រការ ១៦.-**

សម្រាប់ការអនុវត្តឆ្នាំ២០១៦ អាណាប័ក ត្រូវស្នើសុំបុរេប្រទានសាច់ប្រាក់លើកដំបូងសម្រាប់ទ្រទ្រង់ចំណាយប្រតិបត្តិការបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ រយៈពេល៦ខែ ជូនគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ។

## ជំពូកទី ៥

## អវសានប្បញ្ញត្តិ

**ប្រការ ១៧.-**

រាល់បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងប្រកាសអន្តរក្រសួងនេះត្រូវទុកជានិរាករណ៍។

**ប្រការ ១៨.-**

ថ្នាក់ដឹកនាំ នាយកខុទ្ទកាល័យ អគ្គលេខាធិការ អគ្គនាយក អគ្គាធិការ ប្រធាននាយកដ្ឋាន និងប្រធានគ្រប់អង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ត្រូវទទួលបន្ទុកអនុវត្តប្រកាសអន្តរក្រសួងនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី១៧ ខែមិថុនា ឆ្នាំ ២០១៦

**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន**

**រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**អ៊ិត សំហេង**

កន្លែងទទួល÷
- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- អគ្គសវនកម្មជាតិ
- ក្រសួងទំនាក់ទំនងព្រឹទ្ធសភា រដ្ឋសភា និងអធិការកិច្ច
- សាលារាជធានី ខេត្ត
- ដូចប្រការ១៨
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ